**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.០១៦.៩៧១.ណ.ស.ណ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO)**

**លើកទី ២**

យោងតាមសេចក្តីជូនដំណឹងលេខ ធ១.០១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃលើប្រតិបត្តិការ LPCO លើកទី២ ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០នាទីព្រឹក ដល់ ១២:០០នាទីថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦
- កាលវសាន : ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ៤០.០០០.០០០.០០០ (សែសិបប៊ីលាន) រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន) រៀល
- ទឹកប្រាក់ដេញថ្លៃអតិបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន) រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- និតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល)និង អត្រាការប្រាក់ដេញថ្លៃជាភាគរយ(ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD(ជារៀលឬដុល្លារ) ត្រូវមានតណប្រតិទាន យ៉ាងតិចបីខែ ។ NCD ជាប្រាក់ដុល្លារត្រូវកំណត់ haircut ៥% នៃតម្លៃចារឹក ។ ចំពោះ NCD ជាប្រាក់រៀលមិនមានការកំណត់ haircut ទេ ។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh ។ ក្នុងករណីដែលសារអេឡិចត្រូនិកមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា ឲ្យបានមុនម៉ោង ១២:០០ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០នាទីរសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ ៖ ០១២៩៦៩៦៤៤ / ០៧៧៩៦១៩៩១